ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខៈ បព ១៧/២០២៥ កបទ.សអ

**សេចក្តីប្រកាសព័ត៌មាន**

## ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានរៀបចំទស្សនកិច្ចទៅខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានរៀបចំដំណើរទស្សនកិច្ចទៅកាន់ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប នៅថ្ងៃទី១ និងទី២ ខែសីហា ឆ្នាំ២០២៥ ដោយមានការចូលរួមពីប្រធាន តំណាងស្ថានបេសកកម្មការទូត និងទីភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិ (អ.ស.ប) ដែលមានចំនួនសរុប២៦រូប។

គណៈប្រតិភូបានចុះទៅពិនិត្យស្ថានភាពជាក់ស្តែងនៅតំបន់ចំនួនពីរគឺ នៅភូមិថ្មដូន និងភូមិតាមាន់សែនជ័យ ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដែលមានហេដ្ឋារចនាសម្ព័ន្ធស៊ីវិលជាច្រើនរួមមានផ្ទះប្រជាពលរដ្ឋ សាលារៀន មណ្ឌលសុខភាព ទីសក្ការៈបូជា និងវត្តអារាម ត្រូវបានបំផ្លិចបំផ្លាញដោយសារ ការទម្លាក់គ្រាប់បែក និងគ្រាប់ផ្លោងរបស់ថៃ ក្នុងអំឡុងពេលជម្លោះព្រំដែនកម្ពុជា-ថៃ នាពេលថ្មីៗនេះ នៅមុនពេលបទឈប់បាញ់ថ្ងៃទី២៨ខែកក្កដា ចូលជាធរមាន។

គណៈប្រតិភូបានចុះសួរសុខទុក្ខជនភៀសសឹកចំនួន៨៤០គ្រួសារ នៅវត្តភ្នំថ្មកំបោរ ភូមិពោធិ៍ចាស់ ឃុំបេង ខេត្តឧត្តរមានជ័យ និងចំនួន៦៩០គ្រួសារ នៅវត្តប្រាសាទបន្ទាយស្រី ស្រុកសូទ្រនិគម ខេត្តសៀមរាប ដែលកំពុងស្នាក់នៅបណ្តោះអាសន្ននៅទីតាំងទាំងពីរនេះ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយកម្ពុជាបានឱ្យដឹងថា មានគ្រួសារសរុបចំនួន៤០.៨៧០ ស្មើនឹង១៣៦.០១៣ នាក់ មកពីខេត្តជាប់ព្រំដែនចំនួនប្រាំដែលរងផលប៉ះពាល់ បានបាត់បង់ទីលំនៅដ្ឋាន។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានពាំនាំនូវសេចក្តីស្រឡាញ់ សមានចិត្តដ៏ជ្រាលជ្រៅ និងការចូលរួមរំលែកទុក្ខរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជូនបងប្អូនទាំងអស់ដែលបានរងផលប៉ះពាល់ដោយសារជម្លោះព្រំដែននាពេលថ្មីៗនេះ ជាពិសេសជូនគ្រួសារជនស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលបានពលី ឬរងរបួស។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានបញ្ជាក់ជូនបងប្អូនជនភៀសសឹកនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចខិតខំប្រឹងប្រែងអស់ពី

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

លទ្ធភាព ក្នុងការជួយសម្រាលការលំបាករបស់បងប្អូន និងការវិលត្រលប់ទៅលំនៅដ្ឋានវិញដោយសុវត្ថិភាព អោយបានឆាប់តាមដែលអាចធ្វើទៅបាន ដោយធានានូវបទឈប់បាញ់ពេញលេញ និងប្រកបដោយប្រសិទ្ធភាព។

សមាជិកអង្គទូត និងភ្នាក់ងារជំនាញរបស់អ.ស.ប ដែលបានចូលរួមក្នុងទស្សនកិច្ចនេះបានចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំចំពោះក្រុមគ្រួសារជនរងគ្រោះ ដែលបាត់បង់មនុស្សជាទីស្រឡាញ់របស់ខ្លួន ហើយបានសម្តែងការអាណិតអាសូរយ៉ាងស្មោះជូនចំពោះបងប្អូន ដែលរងផលប៉ះពាល់ដោយការប៉ះទង្គិចប្រដាប់អាវុធនេះ។ គណៈប្រតិភូបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការគោរព និងការអនុវត្តកិច្ចព្រមព្រៀងបទឈប់បាញ់អោយបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព ដែលជាជំហានដ៏សំខាន់មួយឆ្ពោះទៅសម្រេចបានដំណោះស្រាយដោយសន្តិវិធី និងយូរអង្វែង។ ជារួម សមាជិកអង្គទូត និងភ្នាក់ងារជំនាញ បានសម្តែងនូវក្តីសង្ឃឹមថាសន្តិភាពពេញលេញនឹងត្រូវបានស្តារឡើងវិញក្នុងពេលឆាប់ៗនេះ ហើយបានស្វាគមន៍ចំពោះកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ (ចាប់ពីថ្ងៃទី ៤ ដល់ថ្ងៃទី ៧ ខែសីហាឆ្នាំ២០២៥)។ សមាជិកអង្គទូត និងភ្នាក់ងារជំនាញរបស់អ.ស.ប ក៏បានគាំទ្រយ៉ាងមុតមាំចំពោះការបន្តកិច្ចសន្ទនារវាងកម្ពុជា និងថៃ ក្នុងការសម្រេចបានសន្តិភាពយូរអង្វែង ដើម្បីអនុញ្ញាតឱ្យបងប្អូនជនភៀសសឹកអាចត្រឡប់ទៅលំនៅដ្ឋានវិញ និងបន្តជីវភាពរស់នៅប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ។

ក្នុងដំណើរទស្សនកិច្ចនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** ក៏មានកម្មវិធីដាច់ដោយឡែកមួយទៀត ដោយបានអញ្ជើញទៅសួរសុខទុក្ខ និងប្រគល់អំណោយមួយចំនួនជូនដល់កងកម្លាំងប្រដាប់អាវុធនៅក្រុងសំរោង ខេត្តឧត្តរមានជ័យ។

ថ្ងៃអាទិត្យ ៩កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៥

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

Nº. PR 17/2025 MFA.IC

Press Release

## Deputy Prime Minister PRAK Sokhonn hosted Field Visit to Oddar Meanchey and Siem Reap

**His Excellency Deputy Prime Minister PRAK Sokhonn**, Minister of Foreign Affairs and International Cooperation hosted a field visit to the provinces of Oddar Meanchey and Siem Reap, on 1-2 August 2025, which was participated by heads and representatives of 26 Diplomatic Missions and specialized agencies of the United Nations.

The visiting delegation viewed the ground situation of two areas in Thmor Daun village and Tamone Sen Chey village, Kok Mon commune, Banteay Ampil district, Oddar Meanchey province, where several civilian structures, including homes, schools, health centers and religious site were damaged by Thai aerial bombing and shelling during the recent Cambodia-Thailand border conflict, before the 28 July ceasefire came into effect.

The delegation visited 2 temporary shelters for internally displaced people. The delegation interacted with 440 displaced families at the Phnom Thmor Kambor pagoda in Por Chas Village, Beng Commune, Oddar Meanchey Province, and 690 families at Prasat Banteay Srei pagoda in Sotnikum District, Siem Reap Province. According to the National Committee for Disaster Management of Cambodia, a total of 40,872 households or 136,013 persons, were displaced in five affected border provinces.

His Excellency Deputy Prime Minister PRAK Sokhonn conveyed love and heartfelt sympathies and condolences from **Samdech Akka Moha Sena Padei Techo HUN Sen**, President of the Senate, and **Samdech Moha Borvor Thipadei HUN Manet**, Prime Minister of the Kingdom of Cambodia to everyone affected by the recent border



Address : Nº 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

conflict, in particular families of the civilians and armed forces who have been killed or injured. He assured the displaced communities of the firm commitment of the Royal Government of Cambodia to making every possible effort to alleviate their hardship and safe return to their homes as soon as possible, by ensuring full and effective ceasefire.

Members the diplomatic corps and United Nations Agencies who joined the site visit expressed deep condolences to the bereaved families for the loss of their loved ones, and conveyed sincere sympathies to all those affected by the armed clashes. They emphasized the importance of full respect and effective implementation of the ceasefire agreement, as a critical step toward achieving a peaceful and lasting resolution. In general, they expressed hope that complete peace would be restored soon, and welcomed the upcoming meeting of the General Border Committee (from 4 to 7 August 2025). They voiced strong support for the continued dialogue between Cambodia and Thailand, with the goal of achieving a durable peace that would enable displaced communities to return homes and resume their lives in safety and dignity.

During this visit, His Excellency Deputy Prime Minister PRAK Sokhonn also had a separate program to visit and hand over some gifts to the Cambodian armed forces, in Samrong City, Oddar Meanchey Province.

Phnom Penh, 03 August 2025

## បញ្ជីតំណាងអង្គទូត និងទីភ្នាក់ងារអង្គការសហប្រជាជាតិ (អសប)ចូលរួម ទស្សនកិច្ចស្វែងយល់នៅខេត្តឧត្តរមានជ័យ និងសៀមរាប ពីថ្ងៃទី០១-០២ ខែសីហា ឆ្នាំ២០២៥

| ល.រ. | ឯកអគ្គរដ្ឋទូត និងតំណាង | តួនាទី |
|---|---|---|
| ១ | ប្រ៊ុយណេដារូស្សាឡាម | ឯកអគ្គរាជទូត + ១ |
| ២ | សាធារណរដ្ឋសិង្ហបុរី | ឯកអគ្គរដ្ឋទូត |
| ៣ | សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន | ឯកអគ្គរដ្ឋទូត + ១ |
| ៤ | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | ឯកអគ្គរដ្ឋទូត |
| ៥ | សាធារណរដ្ឋតួកគីយេ | ឯកអគ្គរដ្ឋទូត |
| ៦ | សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ | ឯកអគ្គរដ្ឋទូត |
| ៧ | ចក្រភពអង់គ្លេស | ឯកអគ្គរដ្ឋទូត |
| ៨ | ប្រទេសជប៉ុន | ឯកអគ្គរាជទូត + ១ |
| ៩ | សហភាពអឺរ៉ុប | ឯកអគ្គរដ្ឋទូត |
| ១០ | សាធារណរដ្ឋឥណ្ឌូណេស៊ី | ឯកអគ្គរដ្ឋទូត + ១ |
| ១១ | សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា | ឯកអគ្គរដ្ឋទូត |
| ១២ | ប្រទេសម៉ាឡេស៊ី | ឯកអគ្គរាជទូត |
| ១៣ | សាធារណរដ្ឋប្រជាមានិតចិន | ឯកអគ្គរដ្ឋទូត + ២ |
| ១៤ | ប្រទេសអូស្ត្រាលី | ឯកអគ្គរដ្ឋទូត |
| ១៥ | សាធារណរដ្ឋឥណ្ឌា | ឯកអគ្គរដ្ឋទូត |
| ១៦ | សាធារណរដ្ឋកូរ៉េ | ភារៈធារីស្ដីទី |
| ១៧ | សាធារណរដ្ឋបារាំង | ភារៈធារីស្ដីទី |
| ១៨ | សាធារណរដ្ឋហ្វីលីពីន | ភារៈធារីស្ដីទី + ១ |
| ១៩ | ប្រទេសកាណាដា | ភារៈធារីស្ដីទី |
| ២០ | សាធារណរដ្ឋសង្គមនិយមវៀតណាម | អនុប្រធានបេសកកម្ម + ១ |
| ២១ | សហព័ន្ធរុស្ស៊ី | លេខាធិការទី៣ |
| ២២ | សហរដ្ឋអាមេរិក | ប្រធានផ្នែកនយោបាយ និងសេដ្ឋកិច្ច |
| | **តំណាងទីភ្នាក់ងារ អសប** | |
| ២៣ | អង្គការស្បៀងអាហារ និងកសិកម្ម (FAO) | ជំនួយការអ្នកតំណាង អង្គការប្រចាំប្រទេស |
| ២៤ | អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) | មន្ត្រីទំនាក់ទំនងរដ្ឋាភិបាល និង ជនចំណាកស្រុក |
| ២៥ | អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) | ជំនួយការអ្នកតំណាង អង្គការប្រចាំប្រទេស |
| ២៦ | អង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) | អនុប្រធានអង្គការ |
| | **សរុប ២៦ តំណាងអង្គទូត និងទីភ្នាក់ងារអង្គការសហប្រជាជាតិ** | |

List of Representatives of Diplomatic Corps and UN Specialized Agencies who attend a field visit to Oddar Meanchey and Siem Reap Provinces on Friday, 01-02 August 2025

| Nº | Embassy | Position |
|---|---|---|
| 1 | Brunei | Ambassador + 1 |
| 2 | Singapore | Ambassador |
| 3 | Pakistan | Ambassdor + 1 |
| 4 | Lao PDR | Ambassador |
| 5 | Türkiye | Ambassador |
| 6 | Germany | Ambassador |
| 7 | United Kingdom | Ambassador |
| 8 | Japan | Ambassador + 1 |
| 9 | European Union | Ambassador |
| 10 | Indonesia | Amabassador + 1 |
| 11 | Myanmar | Ambassador |
| 12 | Malaysia | Ambassador |
| 13 | China | Ambassador + 1 + 1 |
| 14 | Australia | Ambassador |
| 15 | India | Ambassador |
| 16 | Republic of Korea | CDA |
| 17 | France | CDA |
| 18 | Philippines | CDA + 1 |
| 19 | Canada | CDA |
| 20 | Viet Nam | DCM + 1 |
| 21 | Russia | 3rd Secretary |
| 22 | United States of America | Political and Economic Section Chief |
| UN Specialized Agencies | | Position |
| 23 | FAO | Assistant to FAO Representative |
| 24 | IOM | Government Liaison and Migrant Protection Officer |
| 25 | UNFPA | Assistant Representative |
| 26 | WFP | Deputy Representative of WFP |
| Total 26<br>Representatives of Diplomatic Corps and UN Specialized Agencies | | |


ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
Ministry of Foreign Affairs
and International Cooperation
ជុំរុំជនភៀសសឹក វត្តភ្នំថ្មកំបោរ ភូមិពោធិ៍ចាស់ ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ


ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
Ministry of Foreign Affairs
and International Cooperation
Vital
Vital
តំបន់ប្រតិបត្តិការសឹងរេង ក្រុងសំរោង ខេត្តឧត្តរមានជ័យ


ភូមិថ្មដូន ស្រុកគោកមន ខេត្តឧត្តរមានជ័យ


ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
Ministry of Foreign Affairs
and International Cooperation